# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

# អនុស្សរណៈនៃការយោគយល់

រវាង

# គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

និង

# អង្គការ ម៉ារីស៊ី (MARICI)

ស្តីពី

# សកម្មភាពបង្ការទប់ស្កាត់ ប្រយុទ្ធប្រឆាំងរាល់ទម្រង់នៃអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចលើកុមារ

២០២៤- ២០២៦

# បុព្វកថា

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) និងអង្គការម៉ារីស៊ី ដែលតទៅនេះកំណត់ហៅថា "គូភាគី"

ដោយមានបំណងសហប្រតិបត្តិការលើការងារមនុស្សធម៌នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីរួមចំណែកលើកកម្ពស់សុខុមាលភាពសង្គម តាមរយៈកិច្ចការពារសិទ្ធិកុមារ ព្រមទាំងបង្ការ ទប់ស្កាត់ និងការពារកុមារពីអំពើជួញដូរ អំពើរំលោភបំពានផ្លូវភេទ និងអំពើកេងប្រវ័ញ្ចគ្រប់ទម្រង់

ដោយធានាប្រសិទ្ធភាពការងារបង្ការ ទប់ស្កាត់ ប្រយុទ្ធប្រឆាំងរាល់ទម្រង់ នៃការកេងប្រវ័ញ្ចរំលោភបំពានផ្លូវភេទ និងអំពើជួញដូរមនុស្ស

ដោយឈរលើមូលដ្ឋាននៃផលប្រយោជន៍ទៅវិញទៅមក និងតម្រូវការរបស់ភាគីនីមួយៗ

ដោយគោរពច្បាប់ជាតិ និងច្បាប់អន្តរជាតិ ព្រមទាំងមូលដ្ឋានគ្រឹះនៃឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដី និងការមិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងនៃព្រះរាជាណាចក្រកម្ពុជា។ សកម្មភាពទាំងឡាយនឹងត្រូវធ្វើឡើងតាមរយៈយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ផ្អែកលើច្បាប់ គោលនយោបាយជាតិ អន្តរជាតិ និងផែនការយុទ្ធសាស្ត្រជាតិរបស់ គ.ជ.ប.ជ ព្រមទាំងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា។

គូភាគីបានព្រមព្រៀងគ្នាដូចតទៅ៖

## ប្រការ១
## គោលបំណង

អនុស្សរណៈនៃការយោគយល់នេះមានគោលបំណងកំណត់បែបបទ និងនីតិវិធីសម្រាប់កិច្ចសហប្រតិបត្តិការរវាងគូភាគី ដើម្បីលើកកម្ពស់សមត្ថភាព សុវត្ថិភាព ព្រមទាំងផ្តល់កិច្ចការពារសិទ្ធិកុមារ និងស្ត្រី ពីរាល់ទម្រង់នៃអំពើជួញដូរមនុស្ស ក៏ដូចជាអំពើកេងប្រវ័ញ្ចផ្សេងៗទៀត។

សេចក្តីបរិយាយអំពីគម្រោង មានចែងនៅក្នុងឧបសម្ព័ន្ធនៃអនុស្សរណៈនៃការយោគយល់នេះ។

## ប្រការ២
## វិសាលភាពនៃកិច្ចសហប្រតិបត្តិការ

កិច្ចសហប្រតិបត្តិការ ដើម្បីលើកកម្ពស់សមត្ថភាព សុវត្ថិភាព ព្រមទាំងផ្តល់កិច្ចការពារសិទ្ធិកុមារ និងស្ត្រី ពីរាល់ទម្រង់នៃអំពើជួញដូរមនុស្ស ក៏ដូចជាអំពើកេងប្រវ័ញ្ចផ្សេងៗទៀត មានដូចខាងក្រោម៖

១. រៀបចំគម្រោង «បណ្តាញសុវត្ថិភាពស្ត្រីនិងកុមារ ក្នុងសហគមន៍ដែលមានហានិភ័យខ្ពស់»និងផែនការសកម្មភាពរួមគ្នាប្រចាំឆ្នាំ សម្រាប់រយៈពេលបីឆ្នាំ ដើម្បីជំរុញការអនុវត្តអនុស្សរណៈនេះឱ្យមានប្រសិទ្ធភាព។

២.រៀបចំកិច្ចប្រជុំទៀងទាត់ សម្រាប់ត្រីមាស ឆមាស និងប្រចាំឆ្នាំ ដើម្បីតាមដានវឌ្ឍនភាពនៃការអនុវត្តគម្រោង។

៣.ចុះតាមដាន ត្រួតពិនិត្យ និងវាយតម្លៃគម្រោងរួមគ្នាតាមគោលដៅនៅរៀងរាល់ឆមាស។

៤.ធ្វើរបាយការណ៍បូកសរុបប្រចាំឆ្នាំ ស្តីពីលទ្ធផលនៃការអនុវត្តអនុស្សរណៈ និងលើកទិសដៅបន្ត ព្រមទាំងផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីឧត្តមានុវត្តន៍នៃគម្រោង ដើម្បីចែករំលែកទៅដៃគូដទៃទៀត។

## ប្រការ៣

## ការទទួលខុសត្រូវរបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានព្រមព្រៀងដូចខាងក្រោម៖

ក.អនុញ្ញាតឱ្យអង្គការម៉ារីស៊ីធ្វើកិច្ចសហប្រតិបត្តិការក្នុងគោលដៅប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដោយអនុវត្តទៅតាមគោលការណ៍ច្បាប់ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនៃព្រះរាជាណាចក្រកម្ពុជា។

ខ.ដាក់ចេញនូវគោលការណ៍ណែនាំ និងអនុញ្ញាតឱ្យ គណៈកម្មាធិការរាជធានីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.រ.ប.ជ) និងគណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ខ.ប.ជ) ព្រមទាំងរដ្ឋបាលរាជធានីខេត្តពាក់ព័ន្ធ ដោយសហការជាមួយអង្គការម៉ារីស៊ីដែលធ្វើសកម្មភាពនៅក្នុងភូមិសាស្ត្ររបស់ខ្លួន។

គ. សម្របសម្រួលទទួលព័ត៌មាន និងរបាយការណ៍ពីអង្គការម៉ារីស៊ី ស្តីពីសកម្មភាព លទ្ធផល និងបទពិសោធន៍ ឬភាពប្រឈមនានាដែលត្រូវរួមគ្នាដោះស្រាយ។

ឃ.សហការជាមួយអង្គការម៉ារីស៊ី រៀបចំកិច្ចប្រជុំបច្ចេកទេស និងផ្សព្វផ្សាយអំពីការអនុវត្តអនុស្សរណៈដល់អង្គការដៃគូរបស់ម៉ារីស៊ី ជាមួយគណៈកម្មាធិការរាជធានីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.រ.ប.ជ) និងគណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ខ.ប.ជ)។

ង.អនុញ្ញាតឱ្យអង្គការម៉ារីស៊ី និងអង្គការដៃគូចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់រៀបចំផែនការជាតិ គោលនយោបាយ ឬលិខិតបទដ្ឋានចាំបាច់នានាដែលពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់អង្គការម៉ារីស៊ី។

ច.រៀបចំកិច្ចប្រជុំត្រីមាស និងកិច្ចប្រជុំវិសាមញ្ញតាមការចាំបាច់ ដើម្បីតាមដានភាពរីកចម្រើនក្នុងការអនុវត្តគម្រោង ភាពប្រឈមដែលត្រូវដោះស្រាយ និងចែករំលែកនូវបទពិសោធន៍ដែលទទួលបានទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

## ប្រការ៤

## ការទទួលខុសត្រូវរបស់អង្គការម៉ារីស៊ី

អង្គការម៉ារីស៊ី បានព្រមព្រៀងដូចខាងក្រោម៖

ក. គ្រប់គ្រងថវិកាបានមកពីសប្បុរសជននៅការិយាល័យកណ្តាលរបស់អង្គការនៅសហរដ្ឋអាម៉េរិក អនុវត្តសកម្មភាពរបស់គម្រោងឱ្យមានប្រសិទ្ធភាពតាមគោលដៅ និងគោរពយ៉ាងខ្ជាប់ខ្ជួននូវច្បាប់ និងបទប្បញ្ញត្តិទាំងឡាយរបស់ព្រះរាជាណាចក្រកម្ពុជា។

២

ខ. មិនអនុញ្ញាតឱ្យភ្នាក់ងាររបស់ខ្លួនចូលរួមនូវរាល់សកម្មភាពទាំងឡាយណា ដែលអាចប៉ះពាល់ដល់សុវត្ថិភាព ស្ថិរភាព និងសណ្តាប់ធ្នាប់សង្គម ឬសកម្មភាពដទៃទៀតដែលអាចបង្កអន្តរាយដល់សន្តិសុខជាតិ ឯកភាពជាតិ វប្បធម៌ និងប្រពៃណីរបស់ប្រជាជនកម្ពុជា។

គ. ប្រតិបត្តិនូវរាល់សកម្មភាពមនុស្សធម៌ជួយដល់កុមារ និងស្ត្រីរងគ្រោះ និងងាយរងគ្រោះស្របតាមផែនការសកម្មភាព និងគោលនយោបាយរបស់ខ្លួនដោយអនុលោមតាមខ្លឹមសារនៃអនុស្សរណៈ និងប្រកាន់ខ្ជាប់នូវគោលការណ៍នៃកិច្ចសហប្រតិបត្តិការ។

ឃ. ពង្រឹងភាពជាដៃគូតាមរយៈអគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ) ជាមួយនឹងលេខាធិការដ្ឋាននៃគណៈកម្មាធិការរាជធានីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.រ.ប.ជ) និងគណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ខ.ប.ជ)ដើម្បីសម្របសម្រួលដល់ការផ្លាស់ប្តូរព័ត៌មានរវាងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ពាក់ព័ន្ធនឹងសកម្មភាព ដែលបានអនុវត្ត និងទិសដៅបន្ត។

ង. ចូលរួមសកម្មភាពបង្ការទប់ស្កាត់ រាល់ទម្រង់នៃអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ជាពិសេសលើកុមារ និងស្ត្រី។

ច. ចូលរួមសហការពង្រឹងសមត្ថភាពដល់មន្ត្រីជួរមុខដើម្បីផ្តល់កិច្ចការពារសិទ្ធិ សុវត្ថិភាព និងផលប្រយោជន៍ដល់កុមារ និងស្ត្រីរងគ្រោះ និងងាយរងគ្រោះ។

ឆ. ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ស្តីពីការផ្លាស់ប្តូរណាមួយទាក់ទងនឹងអាសយដ្ឋាន អ្នកតំណាង និងនាយកគម្រោងដែលបានចាត់តាំង។

## ប្រការ៥

## ការដោះស្រាយវិវាទ

រាល់វិវាទដែលកើតឡើងពាក់ព័ន្ធនឹងការបកស្រាយ និងការអនុវត្តអនុស្សរណៈនេះ ត្រូវដោះស្រាយជាបន្ទាន់ដោយសន្តិវិធីតាមរយៈការពិគ្រោះយោបល់ ឬតាមមធ្យោបាយផ្សេងទៀតដែលគូភាគីព្រមព្រៀង។

## ប្រការ៦

## ការធ្វើវិសោធនកម្ម

អនុស្សរណៈនៃការយោគយល់នេះ អាចធ្វើវិសោធនកម្ម និងកែសម្រួលឡើងវិញ ផ្អែកតាមការព្រមព្រៀងជាលាយលក្ខណ៍អក្សររវាងគូភាគី។ ការធ្វើវិសោធនកម្មនឹងចូលជាធរមានតាមកាលបរិច្ឆេទដែលកំណត់ដោយគូភាគី ហើយនឹងក្លាយជាផ្នែកបំពេញបន្ថែមនៃអនុស្សរណៈនៃការយោគយល់នេះ។

## ប្រការ៧

## សុពលភាព

អនុស្សរណៈនៃការយោគយល់នេះ មានសុពលភាពរយៈពេល៣ (បី)ឆ្នាំ ហើយនឹងអាចបន្តសុពលភាព បានដោយមានការព្រមព្រៀងពីគូភាគី។

## ប្រការ៨

## ការចូលជាធរមាន និងការបញ្ចប់

អនុស្សរណៈនៃការយោគយល់នេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខា។

អនុស្សរណៈនៃការយោគយល់នេះ អាចត្រូវបានបញ្ចប់ដោយភាគីណាមួយក៏បាន ដោយការជូនដំណឹងអំពីបំណងបញ្ចប់ការអនុវត្តអនុស្សរណៈនៃការយោគយល់នេះ ជូនភាគីម្ខាងទៀតជាលាយលក្ខណ៍អក្សរ។ ក្នុងករណីនេះ អនុស្សរណៈនៃការយោគយល់នេះ នឹងត្រូវបញ្ចប់ក្នុងរយៈពេល ៦០(ហុកសិប) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការទទួលបានការជូនដំណឹង។

អនុស្សរណៈនៃការយោគយល់នេះពុំមែនជាកិច្ចព្រមព្រៀង និងពុំបង្កើតសិទ្ធិ និងកាតព្វកិច្ចណាមួយឡើយ។

ចុះហត្ថលេខានៅថ្ងៃទី....១៦....ខែ....កញ្ញា....ឆ្នាំ២០២៤ ជា ០២(ពីរ) ច្បាប់ដើមជាអក្សរខ្មែរ។

**គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស**

**អនុប្រធានអចិន្ត្រៃយ៍**

**លោកជំទាវ ជូ ប៊ុនអេង**

**តំណាងអង្គការម៉ារីស៊ី(MARICI)**

**ប្រចាំនៅប្រទេសកម្ពុជា**

**នាយកប្រចាំប្រទេស**

**លោក ឌី ធឿត**

# ឧបសម្ព័ន្ធ

## សេចក្តីបរិយាយអំពីគម្រោង

| | | |
|---|---|---|
| ឈ្មោះស្ថាប័ន | ៖ | អង្គការម៉ារីស៊ី |
| ប្រភេទស្ថាប័ន | ៖ | អង្គការបរទេសក្នុងស្រុក |
| លិខិតអនុញ្ញាត | ៖ | ដោយរាជរដ្ឋាភិបាលកម្ពុជាចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៤ |
| អាសយដ្ឋានៈ | ៖ | ផ្ទះលេខ៦៣ ផ្លូវ១៩៧២ ភូមិពោងពាយ សង្កាត់ភ្នំពេញថ្មី<br>ខណ្ឌសែនសុខ រាជធានីភ្នំពេញ |
| លេខទូរសព្ទទំនាក់ទំនង | ៖ | ០១២ ២៩ ៥៣ ៥០ / ០១១ ៤២៩ ៧២៩ |
| អ៊ីម៉ែល | ៖ | dy@marici.org |
| ឈ្មោះគម្រោងសកម្មភាព | ៖ | បង្ការទប់ស្កាត់ និងគាំពារកុមារ និងស្ត្រីពីគ្រប់ទម្រង់នៃអំពើជួញដូរមនុស្ស |
| ទីតាំងគម្រោង | ៖ | រាជធានីភ្នំពេញ ខេត្តសៀមរាប និងខេត្តបាត់ដំបង |
| ដៃគូអនុវត្តគម្រោង | ៖ | គ្មាន |
| ថវិកាអនុវត្តន៍គម្រោង | ៖ | ៣,០០០,០០០$ (បីលានដុល្លារអាម៉េរិក) រយៈពេល៣ឆ្នាំ |
| អ្នកផ្តល់ថវិកាគាំទ្រគម្រោង | ៖ | នៅការិយាល័យកណ្តាលរបស់អង្គការម៉ារីស៊ីប្រចាំសហរដ្ឋអាម៉េរិក |
| កាលបរិច្ឆេទចាប់ផ្តើម | ៖ | ថ្ងៃទី...១៦...ខែ...កញ្ញា...ឆ្នាំ ២០២៤ |
| កាលបរិច្ឆេទបញ្ចប់ | ៖ | ថ្ងៃទី...១៦...ខែ...កញ្ញា...ឆ្នាំ២០២៦ |
| ចំនួនបុគ្គលិកខ្មែរ | ៖ | បច្ចុប្បន្នមានចំនួន១០នាក់ (ស្រី៤នាក់) |
| ចំនួនបុគ្គលិកបរទេស | ៖ | គ្មាន |